

# សក្តិយស និង លុយកាក់

**Honneur et Argent**

សក្តិយស និង លុយកាក់ ហាក់បីជាហេតុ ដែលនាំឲមេដឹកនាំគណបក្សសង្គ្រោះជាតិ(ចោរ) សុខចិត្តចុះហត្ថលេខាជាមួយគណបក្សប្រជាជន លើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយ ជាប់គាំងស្ទះក្រោយពីការបោះឆ្នោតថ្នាក់ជាតិនាថ្ងៃទី២៨កក្កដាឆ្នាំ២០១៤។

សម-រង្ស៊ី អនាគត «សម្តេច» នឹងបានទទួលកៅអីតំណាង ដែល គ.ជ.ប. គេនឹងប្រគល់ឲ ដោយឥតចាំបាច់មានការបោះឆ្នោតឡើងវិញ។ កៅអីបានបែបនេះ ជាកៅអីថោកទាបបំផុត តែវាគ្មានការរំខានអ្វីដល់អារម្មណ៏របស់ សម-រង្ស៊ី ព្រោះខ្លួនជាតិរច្ឆាន ឥតស្គាល់អ្វីជាធម៍នៃមនុស្សលោកនោះឡើយ គឺថា ឆ្កែ វានៅតែជាឆ្កែជាដ៏រាម។ ឯចំណែក កឹម-សុខា អនាគត «អនុប្រធានរដ្ឋសភា» មានសេចក្តីសោមនស្សក្រៃលែង បានទទួលរង្វាន់ថ្មីនេះ ព្រោះនាមរបស់គាត់ នឹងត្រូវបានក្រុមចោរយកទៅចុះក្នុងបញ្ជី នៃវរៈជនមានឯកសិទ្ធិ (nomenklatura) នៃរបបចោរម័ត(Kleptocratie) នៅស្រុកខ្មែរ។ រីឯ អ្នកជាប់ឆ្នោតតំណាងរាស្ត្រ ៥៤នាក់ទៀត ត្រូវបានទទួលប្រាក់រំពូក គិតតាំងពីថ្ងៃបើករដ្ឋសភាសំរាប់អណត្តិទី៥មក។ តែរង្វាន់ទាំងឡាយនេះ វាមាន បដិភាគ (contrepartie) របស់វា ដែលយើងសន្មត់ថាមាននៅក្រៅផ្លូវការ, ដែលគណបក្សសង្គ្រោះជាតិ(ចោរ) ត្រូវប្រតិបត្តិ ជាដាច់ខាត គឺះ

១. ត្រូវឈប់តវ៉ាជាបន្ទាន់ឲបើកទីលានប្រជាធិបតេយ្យ,

២. ត្រូវបញ្ឈប់សកម្មភាពគ្រប់បែបយ៉ាង ជាដាច់ខាត ប្រឆាំងនឹងរាជរដ្ឋាភិបាល, គណបក្ស

ប្រជាជន,

៣. ត្រូវឈប់លើកមកនិយាយដាច់ខាត ជាសាធារណៈ នូវបញ្ហា អាណាព្យាបាលយួន, អាណានិគមយួន, ព្រំដែនខ្មែរ/យួន, កោះត្រល់ជាអាច់,

៤. ត្រូវឈប់ជ្រៀតជ្រែងក្នុងការបង្ក្រាបរបស់អាជ្ញាធរទៅលើបាតុករតវ៉ាក្នុងលក្ខណៈជានយោបាយក្តី និង ជាវិជ្ជាជីវៈក្តី,

៥. ត្រូវដើរតួជាអ្នកយកអាសាដល់រាជរដ្ឋាភិបាល លើឆាកនយោបាយជាតិ និង អន្តរជាតិ,

៦. ត្រូវគោរព សម្តេចអគ្គមហាសេនាតីតេជោ ហ៊ុន-សែន ជាអ្នកដឹកនាំដ៏ឧត្តុងឧត្តម នៃប្រជាជាតិខ្មែរ, ជាបិតាអាយុជីវិតខ្មែរ ដែលមានថ្ងៃទី៧មករា (១៩៧៩) ជាសក្ខីកម្មជាប្រវត្តិសាស្ត្រជាតិខ្មែរ និង ប្រជាជាតិយៀកណាម,

៧. ត្រូវគណបក្សសង្គ្រោះជាតិ (ចោរ) ទទួលស្គាល់ជាឧឡារិក ថាខ្លួនជាអ្នកចាញ់ឆ្នោត តាមការចុះហត្ថលេខាលើកិច្ចព្រមព្រៀង ក្នុងស្មារតីផ្សះផ្សាជាតិ ជាចាំបាច់ ហើយ សុខចិត្តទទួលតួនាទី ឬ តំណែងណា ដែលគណបក្សប្រជាជន សុខចិត្តប្រគល់អោយ។

យើងសន្មត់បន្ថែមទៀត នូវប្រការមួយទៀត គឺ ៖ គណបក្សប្រជាជន ដំកល់ទុល សិទ្ធិជាឯកតោភាគី មិនគោរពកិច្ចព្រមព្រៀង នៅពេលណាដែលគណបក្សប្រជាជនយល់ឃើញថា ការប្រតិបត្តិកិច្ចព្រមព្រៀងនេះ វានាំឲមានខាតប្រយោជន៍ដល់គណបក្សប្រជាជន។ ពុំនោះសោត គណបក្សប្រជាជន មិនបើកសិទ្ធិណាមួយឲគណបក្សសង្គ្រោះជាតិ(ចោរ)ឈប់គោរពកិច្ចព្រមព្រៀងនោះបានឡើយ។ បើនៅតែងរឹងទទឹង នឹងបំរាមនេះ មេដឹកនាំគណសង្គ្រោះជាតិត្រូវទទួលទោសក្នុងថ្នាក់បទឧក្រិដ្ឋ។

អ្វីដែលយើងលើកយកមកពិពណ៍នាខាងលើនេះ វាជាផលនៃមនោគតិរបស់យើងពិត តែបើយោងទៅតាមឥរិយាបថ របស់អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ(ចោរ) មនោគតិរបស់យើងនេះ វាអាចមានសេចក្តីពិតច្រើនណាស់ ព្រោះសេចក្តីត្រេកសក្តិយស និង លុយកាក់ វាធ្វើឲជនទាំងនោះភ្លេចអស់នូវអ្វីដែលជាសីលធម៌ ហើយតណ្ហានេះ វាមានជានិច្ចតាំងពីយូរយារមកហើយ នៅជាប់ស្អិតក្នុងសិតិ ដែលជាកត្តាជាកំណត់ (facteur déterminant) សំរាប់ គណបក្សប្រជាជន យកវា មកធ្វើការគ្របសង្កត់នយោបាយ មកលើពួកជនលោភសក្តិយស និង លុយកាក់ នោះឯង។ អ្វីដែលពួកមេដឹកនាំគណបក្សសង្គ្រោះជាតិ កំពុងធ្វើ គឺជាផ្លូវ

ត្រង់ដើររកទីបញ្ចប់នៃអាយុជីវិតគណបក្ស គឺស្លាប់នៅលើបង្គង (ស្លាប់ក្នុងពេលរួមសង្វាត ជាមួយគណបក្សចោរ) ដូចគណបក្ស ហ្វុនសាំងប៉ិច ក្នុងអតីតកាល។ កិច្ចព្រមព្រៀងថ្ងៃទី២២ កក្កដា គ្រាន់ជាដំណោះស្រាយកាលានុវត្តភាព (solution d’opportunité) របស់គណបក្សស ង្គ្រោះជាតិ និង ប្រជាជន តែប៉ុណ្ណោះ ហើយវាគ្មានឥទ្ធិពលអ្វី ទៅលើអាថ៌បញ្ហានយោបាយជាតិ ក្នុងវិស័យសេរីភាពរបស់ប្រជាពលរដ្ឋ, លទ្ធិប្រជាធិបតេយ្យ នោះទេ។ ត្រូវដឹងថា ជ័យជំនះ អកុសល (victoire du mal) នេះវានឹងអាចជាជ័យជំនះស្ថាពរបាន បើប្រជាជនខ្មែរនាំគ្នាបន្ត អង្គុយយំ កើតទុក្ខពីកម្មនៃជីវិតខ្លួន ហើយនាំគ្នាដេកចាំជាថ្មីម្តងទៀតព្រះបាទធម្មិក។ «ខ្លួនទីពឹងខ្លួន» ជាឪវាទព្រះពុទ្ធ ទុកជាសំពៅភេត្រាសំរាប់ជិះឆ្លងសមុទ្រទុក្ខ ក្នុងគោលដៅ ទីបំផុត គឺសេរីភាព សំរាប់កសាងលទ្ធិប្រជាធិបតេយ្យ ដើម្បីសេចក្តីចំរើននៃប្រជាជាតិខ្មែរ៕

**សង្ហា-ឧប**

**ថ្ងៃទី ២៥ កក្កដា ឆ្នាំ២០១៤**